រួមគ្នាស្រឡាញ់នឹងថែរក្សាវប្បធម៌ខ្មែរ!

# ២៨ - រឿង ចៅអាចម៍សេះ




Tablets + o2 Go Flat
Exklusive Tablet-Angebote: Gerät + o2 Go Flat wählen & 240 € sparen.


មានបុរសម្នាក់ អ្នកស្រុកគេហៅថា «ចៅអាចម៍សេះ » ព្រោះនៅខ្ញុំសេដ្ឋីគេឲ្យឃ្វាលសេះប្រហែលជា ៥០ ក្បាល គេឲ្យទៅសង់ខ្ទមនៅបៀតមាត់ទន្លេ ។ បុរសនោះព្យាយាមរំឭកគុណព្រះពុទ្ធ ទោះឃ្វាលសេះក្តី ធ្វើការអ្វីក្តី តែងទន្ទេញជាប់ «អញទៅដេញសេះ សម្មាសម្ពុទ្ធោ អញទៅលើកអាចម៍សេះ សម្មាសម្ពុទ្ធោ » ធ្វើការអ្វីៗក៏ទន្ទេញថា សម្មាសម្ពុទ្ធោដូច្នេះដរាបទៅ ។ ឯអាចម៍សេះនោះទៀតបុរសមិនលើកចោលទេ តែងកើបប្រកការុងទុកបានជាច្រើន ។ថ្ងៃមួយមានសំពៅ ៥០០ មកពីស្រុកចិននាំទំនិញមកលក់ ។ បុរសស្រែកហៅថា « ឲ្យចូលមកនេះសិន» ។ លុះសំពៅចូលមកសួរថា « អ្នករាល់គ្នាបើកសំពៅមកពីណា ?» ។ នាយសំពៅថា « មកពីស្រុកចិន» ។ បុរសថា « អ្នកស្គាល់ស្តេចក្រុងចិនទេ ?» ។ នាយសំពៅថា «ស្គាល់ ព្រោះខ្ញុំនៅជិតព្រះរាជវាំងដែរ » ។ បុរសថា « ស្តេចក្រុងចិននោះជាក្លើអញ ហើយជាមិត្រសម្លាញ់ថ្ងៃមុនរៀងមក បើអ្នកត្រឡប់ទៅស្រុកចិនវិញអញផ្ញើរបស់ទៅក្លើអញផង»នាយសំពៅនោះឆ្លើយថា បាទ ! ហើយនាំគ្នាចេញសំពៅទៅលក់ដូរ, មិនយូរប៉ុន្មាន នាយសំពៅត្រឡប់មកវិញ ចូលទៅរកបុរសនោះ សួរថា «អ្នកឯងមានអ្វីផ្ញើទៅ? យកមកខ្ញុំទៅឥឡូវហើយ » ។ បុរសថាខ្វះអ្វីខ្ញុំរៀបដាក់ក្នុងការុងបម្រុងផ្ញើទៅ» នាយសំពៅក៏ប្រើជើងឈ្នួលឲ្យជញ្ជូនដាក់សំពៅ នូវរបស់ប្រហែល ៤00ការុងដែលសុទ្ធតែការុងពេញដោយអាចម៍សេះ ហើយក៏លាបុរសនោះ ចេញសំពៅទៅស្រុកចិន, ដល់ទៅដំណាក់ផែស្តេចក្រុងចិនហើយក៏បោះយុថ្កា ឡើងទៅក្រាបទូលថា «មានក្លើព្រះអង្គ ផ្ញើរបស់ពីស្រុកខ្មែរមកថ្វាយ ដាក់នឹងការុងច្រើនណាស់ » ។ ស្តេចក្រុងចិនឆ្ងល់ថា « អញមិនដែលទៅស្រុកខ្មែរទេ អញមានក្លើឯណានៅស្រុកខ្មែរ?» ក៏មានព្រះបន្ទូលឲ្យទៅជញ្ជូនការុងអាចម៍សេះនោះ មកដាក់គរនៅមុខព្រះលាន ទ្រង់ឲ្យស្រាយមាត់ការុងចាក់មើល តើជារបស់អ្វីខ្លះ» ដល់ស្រាយទៅ ឃើញសុទ្ធតែដុំមាសគ្រប់ការុង ។ ស្តេចមានព្រះទ័យត្រេកអររកទីបំផុតគ្មាន ក៏ទ្រង់គិតក្នុងព្រះចិន្តាថា «នឹងបានអ្វីផ្ញើទៅគេវិញ, មានតែព្រះរាជបុត្រីមួយព្រះជន្ម ១៨ ឆ្នាំ ព្រះរូប ព្រះឆោមល្អលើសស្រីទាំងអស់ គិតផ្ញើទៅឲ្យគេ, ហើយក៏ទ្រង់ចាត់ឲ្យជាងធ្វើស្គរមួយយ៉ាងធំពាសស្បែកសត្វទាំងសងខាង តែឲ្យមានកន្លែងបើកចេញចូលម្ខាងបាន ហើយក៏ដាក់ព្រះរាជបុត្រីនោះទៅក្នុងស្គរ មានទាំងកន្សែងបក់បោយមួយផង ហើយចាត់បម្រើឲ្យបើកសំពៅយកទៅឲ្យចៅអាចម៍សេះ បម្រើទៅដល់ហើយក៏ស្រែកហៅបុរសនោះថា «ស្តេចក្រុងចិនជាក្លើ ផ្ញើស្គរមួយមកឲ្យអ្នកឯងវាយលេង» ។ បុរសឮដូច្នោះក៏ត្រេកអរណាស់ ។ អ្នកបម្រើយកស្គរទៅចងក្នុងរោងសេះនោះ ។ បុរសនោះក៏ចេះតែវាយលេងទាំងនិយាយផងថា «ក្លើអញស្រឡាញ់អញផ្ញើស្គរនេះមកឲ្យអញវាយលេង»។ ថ្ងៃមួយ បុរសនោះវាយស្គរ ហើយចេញទៅឃ្វាលសេះ ។ នាងដែលនៅក្នុងស្គរចេញមក រៀបបាយទឹកទុកបម្រុងឲ្យបុរសនោះ ហើយចូលទៅក្នុងស្គរ ចេញមករៀបបាយទឹក មកវិញឃើញបាយគិតថា «នរណាអេះ មករៀបបាយឲ្យអញៗឃ្លានបាយ អញស៊ីហើយ» ។ ឯនាងនោះធ្វើដូច្នេះជាច្រើនថ្ងៃ បុរសនោះសង្ស័យនឹកថា «នរណាយកបាយឲ្យអញស៊ីរាល់ថ្ងៃម្ល៉េះ?» ចាំលបមើល ក៏ឃើញនាងដ៏មានរូបល្អឯកចេញពីក្នុងស្គរមក ហើយបក់បោយកន្សែង ឲ្យកើតជាអាហារឡើងមួយរំពេច ។ បុរសនោះក៏ភ័យស្រែកថា « សម្មាសម្ពុទ្ធោ មកពី

ណាល្អម្ល៉េះ ? ហើយក៏រត់ទៅ» ។ នាងនោះចេញតាមបុរសនោះស្រែកថា «សម្លាសម្លាឡើ កុំចាប់អញ អាណិតអញ លែងអញទៅ » ។ នាងថា « ខ្ញុំមិនលែងទេ អ្នកឯងជាប្តីខ្ញុំហើយ ឪពុកខ្ញុំឲ្យខ្ញុំមកនៅធ្វើជាប្រពន្ធអ្នកឯង ព្រោះអ្នកឯងបានផ្ញើមាសប្រាក់ ទៅឲ្យឪពុកខ្ញុំច្រើនណាស់» ។ បុរសថា «ទេ ! ខ្ញុំមិនយកទេ» ។ នាងនោះនិយាយលួងលោមច្រើនដង បុរសក៏ស្ងៀម, នាងដឹកដៃបុរសនោះមករោងសេះវិញ ។ ក្នុងវេលាយប់នោះ នាងអធិដ្ឋានកន្សែងបក់បោយ ហើយបក់ទៅ កើតជាប្រាសាទរាជវាំង មានមនុស្សគឹកកងរំពងនៅក្នុងនោះ ។ ចៅអាចម៍សេះហើយនិងនាងនោះ ក៏នៅលើប្រាសាទ មានមនុស្សបម្រើឆ្វេងស្តាំ ។ អ្នកស្រុកទាំងពួងឃើញហើយ ភ្ញាក់ផ្អើលគ្រប់គ្នា ក៏រត់ទៅប្រាប់សេដ្ឋីជាចៅហ្វាយបុរសនោះថា «មានកើតប្រាសាទរាជវាំង ត្រង់ខ្ទមចៅអាចម៍សេះនោះច្រើនណាស់ » ។ សេដ្ឋីសង្ស័យ រត់ទៅមើលឃើញហើយក៏ភិតភ័យ រត់ទៅទូលស្តេចតាមរឿង ។ ស្តេចទ្រង់ជ្រាប ទ្រង់ចាត់បម្រើ ឲ្យទៅពិនិត្យមើលឃើញពិតដូច្នោះមែន ក៏មានព្រះទ័យទោមនស្សជាខ្លាំងថា «ឈ្មោះណាហ៊ានមកសាងប្រាសាទរាជវាំងក្នុងនគរអញ មានតែអញទេជាស្តេចក្នុងនគរនេះ» ទើបទ្រង់ប្រជុំនាហ្មឺនសព្វមុខមន្ត្រី មានព្រះបន្ទូលចាត់ឲ្យរៀបរេហ៍ពល លើកទៅចាប់ទាំងព្រះអង្គក៏ស្តេចយាងជាមួយផង ។ វេលានោះមានបម្រើទៅប្រាប់ចៅអាចម៍សេះហើយ នឹងប្រពន្ធចៅអាចម៍សេះបានឮ ក៏មានសេចក្តីភិតភ័យណាស់ ។ នាងប្រាប់ប្តីថា «កុំឲ្យភ័យទុកងារឲ្យខ្ញុំច្បាំងនឹងស្តេចនេះវិញ នាងក៏រៀបខ្លួនចេញទៅ ហើយអធិដ្ឋានកន្សែងបក់ កន្សែងបោយឲ្យស្តេចបរាជ័យ ព្រមទាំងរេហ៍ពល ។ ចៅអាចម៍សេះនិងនាងនោះបានសោយរាជ្យជាស្តេចដោយអំណាចដឹងគុណព្រះពុទ្ធ ។

> ***ការខំប្រឹងប្រែង តែងមានផលច្រើន***

កម្ពុជសុរិយា លេខ ១០ – ១១ – ១២ ឆ្នាំ ១៩៣៣ – ៤ ទំព័រ ១៤៩ មិនមានឈ្មោះអ្នករៀបរៀងទេ ។

g+1 +1 Recommend this on Google

Wunsch-Domains bei STRATO

Die Domain mit den gewissen Extras. Bis 02.08. zum Top-Hoster wechseln!

ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ

